ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១២ អយក. ល៩៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសនិស្សិតអាហារូបករណ៍ឱ្យចូលរៀនថ្នាក់បរិញ្ញាបត្រ
## សម្រាប់ឆ្នាំសិក្សា២០១៤-២០១៥

ក្រសួងអប់រំ យុវជន និងកីឡា សូមជូនដំណឹងដល់សាធារណជន សិស្ស និស្សិតឱ្យបានជ្រាបថា ក្រសួងនឹងធ្វើការជ្រើសរើសបេក្ខជនចំនួន៤៩៣៦នាក់ ឱ្យទទួលអាហារូបករណ៍ចូលរៀនថ្នាក់បរិញ្ញាបត្រ សម្រាប់ឆ្នាំសិក្សា២០១៤-២០១៥ ដែលមានព័ត៌មានលម្អិតដូចខាងក្រោម:

**I-សម្រាប់អាហារូបករណ៍ទូទៅ**

**១**-ចំនួនអាហារូបករណ៍មាន ៤៩៣៦នាក់ ត្រូវបានបែងចែក:
- សិស្សទូទៅ ចំនួន ៣០៥២នាក់
- សិស្សអាទិភាពនារី ចំនួន ៦៧៧នាក់
- សិស្សអាទិភាពក្រីក្រ ចំនួន ៩១៤នាក់
- សិស្សអាទិភាពតំបន់ជួបការលំបាក ចំនួន ២៩៣នាក់។

**២-សាកលវិទ្យាល័យ និងវិទ្យាស្ថានដែលបេក្ខជនជ្រើសរើសចូលសិក្សាមាន:**

• **គ្រឹះស្ថានឧត្តមសិក្សារដ្ឋ :**

១- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
២- សាកលវិទ្យាល័យភូមិន្ទកសិកម្ម
៣- សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
៤- សាកលវិទ្យាល័យជាតិគ្រប់គ្រង
៥- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៦- សាកលវិទ្យាល័យជាស៊ីមកំចាយមារ
៧- វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
៨- សាកលវិទ្យាល័យស្វាយរៀង
៩- សាកលវិទ្យាល័យបាត់ដំបង
១០- សាកលវិទ្យាល័យមានជ័យ

• **គ្រឹះស្ថានឧត្តមសិក្សាឯកជន:**

១- សាកលវិទ្យាល័យវេស្ទើន
២- សាកលវិទ្យាល័យមេគង្គកម្ពុជា
៣- សាកលវិទ្យាល័យអាយអាយស៊ីនៃបច្ចេកវិទ្យា
៤- សាកលវិទ្យាល័យអង្គរ
៥- សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ
៦- សាកលវិទ្យាល័យអាស៊ីអឺរ៉ុប
៧- សាកលវិទ្យាល័យចេនឡា
៨- សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា
៩- សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច
១០- សាកលវិទ្យាល័យកម្ពុជា
១១- សាកលវិទ្យាល័យឡាយហ្វ
១២- សាកលវិទ្យាល័យធនធានមនុស្ស
១៣- សាកលវិទ្យាល័យបៀលប្រាយ
១៤- សាកលវិទ្យាល័យហ្សាម៉ាន់
១៥- សាកលវិទ្យាល័យឯកទេសនៃកម្ពុជា
១៦- សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា
១៧- សាកលវិទ្យាល័យអង្គរខេមរា
១៨- សាកលវិទ្យាល័យបញ្ញាជាតិ
១៩- វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសច្ចៈ
២០- វិទ្យាស្ថានក្រុងអង្គរ
២១- វិទ្យាស្ថានសន្តប៉ូល
២២- វិទ្យាស្ថានប្រាយហ្វប
២៣- វិទ្យាស្ថានអប់រំកម្ពុជា
២៤- វិទ្យាស្ថានសិនេរ
២៥- វិទ្យាស្ថានអេសធីខ្មែមិនស៍


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

**៣-សំណុំពាក្យដែលត្រូវបំពេញមាន:**

- **សម្រាប់សិស្សទូទៅ សិស្សអាទិភាពនារី និងសិស្សអាទិភាពតំបន់ជួបការលំបាក**

| | |
|---|---|
| -ពាក្យសុំអាហារូបករណ៍ | ចំនួន ០១ច្បាប់ |
| -បង្កាន់ដៃទទួលពាក្យមានបិទរូបថត (ថតថ្មី) 4 x 6 cm | ចំនួន ០១ច្បាប់ |
| -សលាកបត្រឯកត្តជន (សម្រាប់តែបេក្ខជនត្រូវប្រឡងសំណេរ) | ចំនួន ០១ច្បាប់។ |

- **សម្រាប់សិស្សអាទិភាពក្រីក្រ**

| | |
|---|---|
| -ពាក្យសុំអាហារូបករណ៍ | ចំនួន ០១ច្បាប់ |
| -បង្កាន់ដៃទទួលពាក្យមានបិទរូបថត 4 x 6 cm | ចំនួន ០១ច្បាប់ |
| -ប័ណ្ណគ្រួសារថតចម្លងដែលមានការបញ្ជាក់ពីរដ្ឋអំណាច | ចំនួន ០១ច្បាប់ |
| -កម្រងព័ត៌មានបញ្ជាក់ភាពក្រីក្រ | ចំនួន ០១ច្បាប់ |
| -សលាកបត្រឯកត្តជន (សម្រាប់តែបេក្ខជនត្រូវប្រឡងសំណេរ) | ចំនួន ០១ច្បាប់។ |

**៤-សម្គាល់:** សិស្សពូកែទូទាំងប្រទេសផ្នែកគណិតវិទ្យា រូបវិទ្យា និងអក្សរសិល្ប៍ខ្មែរ ដែលបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៤មានសិទ្ធិបានទទួលអាហារូបករណ៍ទូទៅដោយស្វ័យប្រវត្តិចំនួន១កន្លែង ប្រសិនបើជ្រើសរើសយកមុខជំនាញដែលត្រូវនឹងផ្នែកពូកែរបស់ខ្លួន និងបានមកដាក់ពាក្យសុំអាហារូបករណ៍នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ដែលខ្លួនបានរស់នៅនិងរៀនសូត្រ ចាប់ពីថ្ងៃទី២៧ ខែឧសភា ដល់ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤។

## II-ចំណុចរួមសម្រាប់ការចុះឈ្មោះសុំអាហារូបករណ៍ទូទៅ

**១-លក្ខខណ្ឌចុះឈ្មោះសុំអាហារូបករណ៍ ៖**

ជាសិស្សដែលកំពុងរៀនថ្នាក់ទី១២ ចំណេះទូទៅ និងបំពេញវិជ្ជា និងបេក្ខជនស្វ័យរិនដែលត្រូវប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំ២០១៤។ ដោយឡែកចំពោះបេក្ខជនដែលមានបំណងចុះឈ្មោះសុំអាហារូបករណ៍ចូលរៀនមុខជំនាញប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ត្រូវមានព្រឹត្តបត្រលទ្ធផលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្រដែលមានតម្លៃស្មើ ដោយមិនកំណត់ឆ្នាំប្រឡងជាប់ឡើយ និងត្រូវមានអាយុច្រើនបំផុត ២២ឆ្នាំ ដោយគិតត្រឹមថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤។

**២-កន្លែងទទួលពាក្យ និងកាលបរិច្ឆេទនៃការឈប់ទទួលពាក្យ ៖**

២.១-បេក្ខជនជាសិស្សថ្នាក់ទី១២កំពុងរៀនក្នុងឆ្នាំ២០១៤ ត្រូវមកទទួលសំណុំពាក្យសុំអាហារូបករណ៍ពីវិទ្យាល័យរបស់ខ្លួន ឬពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តដែលគ្រប់គ្រង យកទៅបំពេញចាប់ពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ និងប្រគល់មកវិញ ដោយផុតកំណត់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៤ វេលាម៉ោង ៥.០០ រសៀល ជាកំហិត។

២.២-បេក្ខជនស្វ័យរិន និងបេក្ខជនបំពេញវិជ្ជាត្រូវមកទទួលសំណុំពាក្យពីមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ដែលខ្លួនបានបំពេញសំណុំបែបបទប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៤ យកទៅបំពេញចាប់ពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ និងប្រគល់ជូនមន្ទីរអប់រំ យុវជន និងកីឡាវិញ ដោយផុតកំណត់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៤ វេលាម៉ោង ៥.០០ រសៀលជាកំហិត។

២.៣-ចំពោះបេក្ខជនដែលពុំមានលក្ខខណ្ឌដូចក្នុងចំណុច ២.១ និង២.២ ខាងលើ ហើយដែលបានចុះឈ្មោះសុំអាហារូបករណ៍ចូលរៀនមុខជំនាញ ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ត្រូវមកទទួលយកសំណុំពាក្យសុំអាហារូបករណ៍ពីមន្ទីរអប់រំ យុវជន និងកីឡាណាមួយ យកទៅបំពេញចាប់ពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ និងប្រគល់ជូនមន្ទីរ ឬ សាកលវិទ្យាល័យភូមិន្ទភ្នំពេញវិញ ផុតកំណត់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៤ វេលាម៉ោង ៥.០០ រសៀលជាកំហិត។

**៣-ការប្រកាសលទ្ធផលជ្រើសរើស :**

-លទ្ធផលនៃការជ្រើសរើសនឹងមានបិទផ្សាយនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤ នៅតាមគ្រឹះស្ថានឧត្តមសិក្សានីមួយៗក្នុងរាជធានីភ្នំពេញ បន្ទាប់ពីនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅប្រគល់ទិន្នន័យលទ្ធផលមធ្យមសិក្សាទុតិយភូមិមកនាយកដ្ឋានឧត្តមសិក្សានាថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ វេលាម៉ោង៨:៣០នាទីព្រឹក និងនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៤

នឹងមានបិទផ្សាយនៅតាមគ្រឹះស្ថានឧត្តមសិក្សា តាមមន្ទីរអប់រំ យុវជន និងកីឡា គ្រប់រាជធានី-ខេត្ត និងគ្រប់វិទ្យាល័យដែលមានបេក្ខជនជាប់អាហារូបករណ៍។

-ចំពោះលទ្ធផលបេក្ខជនដែលជ្រើសរើសមុខជំនាញប្រឡងនឹងមានបិទផ្សាយនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ នៅតាមគ្រឹះស្ថានឧត្តមសិក្សានីមួយៗក្នុងរាជធានីភ្នំពេញ។

**៤-សម្គាល់:**

៤.១- សេចក្ដីណែនាំក្នុងការបំពេញពាក្យ លក្ខខណ្ឌកំណត់មុខវិជ្ជា និទ្ទេសតាមមុខវិជ្ជា និទ្ទេសរួម និងចំនួនជ្រើសរើសតាមមុខជំនាញនីមួយៗ និងការកំណត់តំបន់ដាច់ស្រយាល តំបន់ជួបការលំបាកនៅតាមរាជធានី-ខេត្ត មានចែងក្នុងសៀវភៅកម្រងព័ត៌មានដែលបានចែកជូនដល់បេក្ខជន។

៤.២- បេក្ខជន ១នាក់ មានសិទ្ធិចុះឈ្មោះសុំអាហារូបករណ៍បានតែ ១មុខជំនាញ ដោយបង់លេខអារ៉ាប់តាមលំដាប់ពី 1 ដល់ 231 នៅក្នុងសៀវភៅកម្រងព័ត៌មាន និងអាចបានទទួលអាហារូបករណ៍តែ១កន្លែងប៉ុណ្ណោះ។

៤.៣- បេក្ខជនដែលបានដាក់ពាក្យសុំអាហារូបករណ៍មុខជំនាញដែលតម្រូវឱ្យមានការប្រឡង ត្រូវមកមើលឈ្មោះប្រឡង និងប្រគល់សលាកបត្ររបស់ខ្លួន ចាប់ពីថ្ងៃទី០៤ ដល់ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ ជាកំហិតនៅតាមគ្រឹះស្ថានឧត្តមសិក្សាណាមួយ ដែលខ្លួនដាក់ពាក្យស្នើសុំប្រឡងអាហារូបករណ៍ និងត្រូវមកប្រឡងជ្រើស រើសនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤។ ករណីបេក្ខជនពុំបានប្រគល់សលាកបត្រតាមកាលកំណត់នេះទេ បេក្ខជនពុំមានសិទ្ធិចូលប្រឡងបានឡើយ។

៤.៥- បេក្ខជនអាចធ្វើការតវ៉ា ចំពោះលទ្ធផលនៃការជ្រើសរើសនិស្សិតអាហារូបករណ៍ នៅនាយកដ្ឋានឧត្តមសិក្សាក្នុងរយៈពេល ១០ថ្ងៃ គិតចាប់ពីថ្ងៃធ្វើការប្រកាសផ្សព្វផ្សាយលទ្ធផលជ្រើសរើស។

៤.៦- ចំពោះព័ត៌មានលម្អិតផ្សេងៗទៀត សូមទំនាក់ទំនងមកនាយកដ្ឋានឧត្តមសិក្សានូវរៀលរាល់ម៉ោងធ្វើការ តាមរយៈទូរស័ព្ទលេខ ០២៣ ២១៧ ៩៣៧ ឬ ជាមួយគ្រឹះស្ថានឧត្តមសិក្សាដែលបេក្ខជនបានដាក់ពាក្យសុំអាហារូបករណ៍ដែលមានលេខទូរស័ព្ទនៅក្នុងសៀវភៅកម្រងព័ត៌មាន។

៤.៧- ចំពោះបេក្ខជនដែលមានបំណងដាក់ពាក្យសុំអាហារូបករណ៍ ទាក់ទងទៅនឹងមុខជំនាញវិស័យសុខាភិបាលក្នុងឆ្នាំសិក្សា២០១៤-២០១៥នេះ ត្រូវឆ្លងកាត់ការប្រឡងថ្នាក់ជាតិ។ បេក្ខជនត្រូវទៅទទួលពាក្យ និងដាក់ពាក្យជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រឡងថ្នាក់ជាតិ (នាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា ទូរស័ព្ទលេខ ០២៣ ២១៧ ៩៣៧ និងនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងសុខាភិបាល ទូរស័ព្ទលេខ ០២៣ ៤២៨ ៩៣០) ដែលការប្រឡងនេះនឹងមានជូនដំណឹងនាពេលក្រោយ។ **ចំពោះបេក្ខជនដែលបានជាប់ជាស្ថាពរអាហារូបករណ៍ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡារួចហើយ ពុំមានសិទ្ធិទៅប្រឡងយកអាហារូបករណ៍នៅវិស័យសុខាភិបាលទៀតឡើយ។**

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

យក់ ឌិយ

កន្លែងទទួល:

-គ្រប់ស្ថាប័នក្រសួង-មន្ទីរ

-គ្រប់សាលាខេត្ត-ក្រុង

-គ្រប់អគ្គនាយកដ្ឋាន់ នាយកដ្ឋានចំណុះក្រសួងអប់រំ យុវជន និងកីឡា

-គ្រប់មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-រាជធានី

-គ្រប់មន្ទីរវប្បធម៌ និងព័ត៌មាន ខេត្ត-រាជធានី

-គ្រប់គ្រឹះស្ថានឧត្តមសិក្សា-គ្រប់វិទ្យាល័យ

-គ្រប់វិទ្យុទូរទស្សន៍ និងសារព័ត៌មានក្នុងរាជធានីភ្នំពេញ
  “ដើម្បីសូមជួយផ្សព្វផ្សាយ ”

-គ្រប់បេក្ខជនដាក់ពាក្យសុំអាហារូបករណ៍នៅឆ្នាំ២០១៤ “ដើម្បីជាដំណឹង”

-កាលប្បវត្តិ

-ឯកសារ-ន.ឧស